**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

លេខ ៣១០៩ សាក១/សលម

រាជធានីភ្នំពេញ ថ្ងៃទី..០៤..ខែ..កក្កដា..ឆ្នាំ២០១៤

# សេចក្តីសម្រេច
## ស្តីពី
## ការបែងចែកភារកិច្ច និងការទទួលខុសត្រូវរបស់អគ្គនាយក និងអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

## អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្តូរឈ្មោះអគ្គនាយកដ្ឋានរដ្ឋបាល មកជាអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
- យោងតាមការចាំបាច់ របស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ។

## សម្រេច

**ប្រការ ១.–**

កំណត់ធ្វើការបែងចែកភារកិច្ច និងការទទួលខុសត្រូវរបស់អគ្គនាយក និងអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សំដៅធានាប្រសិទ្ធភាពក្នុងការដឹកនាំការអនុវត្ត និងការទទួលត្រូវក្នុងការងារ នៅក្នុងអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ។

**ប្រការ ២.–**

ឯកឧត្តម **ឌុច សុន** អគ្គនាយក ទទួលខុសត្រូវដឹកនាំការងាររួម និងគ្រប់គ្រង បញ្ជា ចាត់ចែងរាល់សកម្មភាពការងារ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ។

**ប្រការ ៣ .—**

ត្រូវបានបែងចែកភារកិច្ចជូនអគ្គនាយករង ដែលជាជំនួយការឱ្យអគ្គនាយក លើកិច្ចការដូចខាងក្រោម ៖

១- ឯកឧត្តម **ចាន់ ចំរើន** អគ្គនាយករង ជួយអគ្គនាយក លើការងារទូទៅប្រចាំនៅលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីសម្របសម្រួលការងារជាមួយដៃគូអភិវឌ្ឍន៍ និងជួយពិនិត្យលើការងារក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលពាក់ព័ន្ធទៅនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការងារពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ

២- ឯកឧត្តម **ឡាយ ឈាវុធ** អគ្គនាយករង ជួយអគ្គនាយក លើការងារនៅលេខាធិការដ្ឋាន គ.ជ.អ.ប ពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍

៣- ឯកឧត្តម **ឌី សុកធាន** ប្រធាននាយកដ្ឋានកិច្ចការនយោបាយ និងជាអគ្គនាយករងទទួលបន្ទុកដឹកនាំ គ្រប់គ្រងការងារនៅនាយកដ្ឋានកិច្ចការនយោបាយ

៤- ឯកឧត្តម **អេង មង្គល** ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអគ្គនាយករង ទទួលបន្ទុកដឹកនាំ គ្រប់គ្រងការងារនៅនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៥- ឯកឧត្តម **ប្រាក់ សំអឿន** ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ និងជាអគ្គនាយករងទទួលបន្ទុកដឹកនាំ គ្រប់គ្រងការងារនៅនាយកដ្ឋានរដ្ឋបាលទូទៅ

៦- ឯកឧត្តម **រាជ សុភន្ធ** អគ្គនាយករង ជួយអគ្គនាយក លើការងារទូទៅនៅលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងការងារទំនាក់ទំនងជាមួយរាជធានី ខេត្ត និងក្រសួង ស្ថាប័ននានា

៧- ឯកឧត្តម **ឡាយ វោហារិទ្ធ** អគ្គនាយករង ជួយអគ្គនាយក លើការងារនៅនាយកដ្ឋានកិច្ចការនយោបាយ ពាក់ព័ន្ធនឹងការងារគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

៨- ឯកឧត្តម **ជា ម៉ុង** អគ្គនាយករង ជួយអគ្គនាយក លើការងារនៅនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពាក់ព័ន្ធនឹងការងារគោលនយោបាយ និងពិនិត្យវាយតម្លៃដល់កម្មសិក្សាការី

៩- ឯកឧត្តម **ឈឹម កាន** អគ្គនាយករង ជួយអគ្គនាយក លើការងារនៅនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពាក់ព័ន្ធនឹងការងារក្របខ័ណ្ឌ និងការងារបណ្តុះបណ្តាល

១០-ឯកឧត្តម **អោក មុនី** អគ្គនាយករង ជួយអគ្គនាយក លើការងារនៅនាយកដ្ឋានរដ្ឋបាលទូទៅ ពាក់ព័ន្ធនឹងការងារសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសំណើសុំមេជាយស្ថាបនាជាតិ

១១-ឯកឧត្តម **ស្វ សុខខេង** អគ្គនាយករង ជួយអគ្គនាយក លើការងារនៅនាយកដ្ឋានរដ្ឋបាលទូទៅ ពាក់ព័ន្ធនឹងការងារវប្បធម៌ សិល្បៈ អប់រំ យុវជន និងកីឡា សុខាភិបាល ទេសចរណ៍ ធម្មការ និងសាសនា

១២-ឯកឧត្តម **ស្វស ប្រាថ្នា** អគ្គនាយករង ជួយអគ្គនាយក លើការងារនៅនាយកដ្ឋានរដ្ឋបាលទូទៅ ពាក់ព័ន្ធនឹងការងារផែនការ វិនិយោគ អភិវឌ្ឍន៍រាជធានី ខេត្ត ការងារកសិកម្ម អភិវឌ្ឍន៍ជនបទ ធនធានទឹក និងបរិស្ថាន

១៣-ឯកឧត្តម **ហ៊ឹ សុជាត** អគ្គនាយករង ជួយអគ្គនាយក លើការងារនៅនាយកដ្ឋានរដ្ឋបាលទូទៅ ពាក់ព័ន្ធនឹងការងារសហប្រតិបត្តិការរវាងខេត្តជាប់ព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងបណ្តាខេត្តជាប់ព្រំដែន នៃប្រទេសជិតខាង ការងារចងសម្ព័ន្ធមេត្រីភាពរវាងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងខេត្ត ក្រុង ស្រុក នៃប្រទេសជាមិត្ត ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងការងារកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

១៤-ឯកឧត្តម **សេង ហ៊ាន់ស៊ី** អគ្គនាយករង ជួយអគ្គនាយក លើការងារពាក់ព័ន្ធនឹងគ្រឿងញៀន សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា និងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

១៥-ឯកឧត្តម **សុង ហេង** អគ្គនាយករង ជួយអគ្គនាយក លើការងារនៅនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

១៦-ឯកឧត្តម **ជាម ប៉េអា** អគ្គនាយករង ជួយអគ្គនាយក លើការងារដែលពាក់ព័ន្ធទៅនឹងគម្រោងបែងចែកដីសម្បទានសង្គមកិច្ច និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (LASED)

១៧-លោកជំទាវ **តៅ សុខម៉ារ៉ា** អគ្គនាយករង ជួយអគ្គនាយក លើការងារឃោសនាការ ព័ត៌មាន កិច្ចការនារី ការងារយេនឌ័រ និងសិទ្ធិកុមារ

១៨-ឯកឧត្តម **ចាន់ សុធា** អគ្គនាយករង ជួយអគ្គនាយក លើការងារនីតិកម្ម ការងារ រចនាសម្ព័ន្ធ និងវិភាគមុខងារ ការងារគាំទ្រការផ្តល់សេវារដ្ឋបាល និងយន្តការច្រកចេញចូលតែមួយ

១៩-ឯកឧត្តម **ព្រុំ ធី** អគ្គនាយករង ជួយអគ្គនាយក តាមដានសភាពការណ៍អសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការងារចំណាកស្រុក ការងារសិទ្ធិមនុស្ស សហជីព បាតុកម្ម កូដកម្ម និងការដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន

២០-ឯកឧត្តម **ហ្វូត ស៊ីនាថ** អគ្គនាយករង ជួយការងារទូទៅដល់ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ។

**ប្រការ ៤.-**

ក្រៅពីភារកិច្ច និងការទទួលខុសត្រូវ ដូចបានកំណត់ខាងលើ អគ្គនាយកអាចប្រគល់ភារកិច្ច និងកិច្ចការជាក់ស្តែងផ្សេងៗទៀត ជូនអគ្គនាយករង តាមការចាំបាច់ ។

**ប្រការ ៥.-**

នៅពេលអគ្គនាយកអវត្តមាន អគ្គនាយករង ដែលទទួលបានការផ្ទេរសិទ្ធិពីអគ្គនាយក ត្រូវទទួលសិទ្ធិដឹកនាំការងារជា "អគ្គនាយកស្តីទី" ។ "អគ្គនាយកស្តីទី" មិនមានសិទ្ធិផ្ទេរការ

ទទួលខុសត្រូវ ទៅឱ្យអគ្គនាយករងណាម្នាក់ទៀតបានឡើយ វៀរលែងតែទទួលបានការអនុញ្ញាតពីអគ្គនាយកជាមុនសិន ។ "អគ្គនាយកស្តីទី" ត្រូវទទួលខុសត្រូវលើកិច្ចការ ដែលខ្លួនបានសម្រេចក្នុងរយៈពេលទទួលសិទ្ធិជា "អគ្គនាយកស្តីទី" ហើយត្រូវរាយការណ៍ជូនអគ្គនាយកអំពីកិច្ចការទាំងនោះ នៅពេលអគ្គនាយកមានវត្តមានវិញ ។

**ប្រការ ៦ .–**

អំពីរបៀបរបបធ្វើការងារ និងការទំនាក់ទំនងរវាងនាយកដ្ឋានជំនាញ ជាមួយអគ្គនាយករងទទួលបន្ទុកមានដូចខាងក្រោម ៖

- ប្រធាននាយកដ្ឋាននីមួយៗ ចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ត្រូវពិគ្រោះយោបល់រាល់កិច្ចការនានា ជាមួយអគ្គនាយករងទទួលជួយកិច្ចការខាងលើ មុននឹងបញ្ជូនឯកសារមកលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដើម្បីដាក់ជូនអគ្គនាយកពិនិត្យ និងសម្រេច ។
- ក្នុងករណីអគ្គនាយករងទទួលបន្ទុកអវត្តមាន ចំពោះកិច្ចការណា ដែលមានលក្ខណៈប្រញាប់សំខាន់ចាំបាច់ ប្រធានយកដ្ឋានអាចដាក់កិច្ចការទាំងនោះ មកលេខាធិការដ្ឋានដើម្បីធ្វើការពិនិត្យ រៀបចំដាក់ជូនអគ្គនាយក ពិនិត្យ សម្រេច តែប្រធាននាយកដ្ឋានត្រូវធ្វើសេចក្តីរាយការណ៍អំពីការងារទាំងនោះ ជូនអគ្គនាយករងទទួលបន្ទុក នៅពេលមានវត្តមានវិញ ។

**ប្រការ ៧ .–**

សេចក្តីសម្រេចនេះ ជំនួសឱ្យសេចក្តីសម្រេចលេខ ៤៦១៦ សសរ/អរម ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ស្តីពីការបែងចែកភារកិច្ច របៀបរបបការងារ និងការទទួលខុសត្រូវ របស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ។

**ប្រការ ៨ .–**

អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ប្រធានលេខាធិការដ្ឋាន មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អគ្គនាយក**

ខួន ស៊ុខ

***ចម្លងជូន៖***

- ថ្នាក់ដឹកនាំក្រសួង
- អគ្គលេខាធិការដ្ឋាន
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ
- អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល
- អគ្គនាយកដ្ឋានពន្ធនាគារ
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

*"ដើម្បីជូនជ្រាប"*

- អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
- នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

*"ដើម្បីអនុវត្តន៍"*

- ឯកសារ-កាលប្បវត្តិ